TSUNAHIRO

## គេហទំព័រសិក្សាភាសាជប៉ុនសម្រាប់ “អ្នករស់នៅដែលជាជនបរទេស”

# តភ្ជាប់ និង អភិវឌ្ឍ
# ការរស់នៅតាមរយៈភាសាជប៉ុន






Bun-chan

គេហទំព័រសិក្សាភាសាជប៉ុនសម្រាប់ជនបរទេសកំពុងរស់នៅក្នុងប្រទេសជប៉ុន ដែលពួកគេអាចសិក្សាភាសាជប៉ុនដើម្បីប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃបាន។

សម្រាប់គេហទំព័រ
ដំណើរការលើ PC SP

tsunagarujp.bunka.go.jp/?lang_id=KH

202303 クメール(カンボジア)語

文化庁
Agency for Cultural Affairs, Government of Japan

# របៀបប្រើ

## ចំណុច ១ ដំណើរការជាមួយពហុភាសា

ដំណើរការជាមួយនឹងពហុភាសាព្រមទាំងអក្សររ៉ូម៉ាជិ។

ភាសាជប៉ុន ភាសាអង់គ្លេស ភាសាចិន(អក្សរសាមញ្ញ អក្សរប្រពៃណី) ភាសាអេស្ប៉ាញ ភាសាព័រទុយហ្គាល់ ភាសាវៀតណាម ភាសាឥណ្ឌូនេស៊ី ភាសាហ្វីលីពីន ភាសានេប៉ាល់ ភាសាខ្មែរ(កម្ពុជា) ភាសាកូរ៉េ ភាសាថៃ ភាសាមីយ៉ាន់ម៉ា ភាសាម៉ុងហ្គោល ភាសាអ៊ុយក្រែន ភាសារុស្ស៊ី



## ចំណុច ២ ជំនាញក្នុងជីវភាពរស់នៅ

ជំនាញក្នុងការរៀនភាសាជប៉ុនដែលត្រូវបានប្រើក្នុងជីវិតប្រចាំថ្ងៃរបស់ជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន។



## ចំណុច ៣ រៀនដោយផ្តោតលើវីដេអូជាគោល

មានឯកសារបង្រៀនជាច្រើនដែលងាយស្រួលយល់ទាំងការមើល និងការស្តាប់ ដូចជាវីដេអូដែលយកគម្រូតាមជីវភាពរស់នៅជាក់ស្តែង និងវីដេអូដែលពន្យល់ពីទម្រង់ប្រយោគ។





### អត្ថបទ

អាចមើលគ្រប់ការសន្ទនាទាំងអស់ដែលមាននៅក្នុងវីដេអូ។

### ចងចាំឃ្លានេះ

អ្នកអាចរៀនដោយយកត់ចំណាំឃ្លាសំខាន់ៗដែលបង្ហាញនៅក្នុងវីដេអូ។

### ចងចាំពាក្យនេះ

អ្នកអាចរៀនពីអត្ថន័យនៃពាក្យសំខាន់ៗដែលបង្ហាញនៅក្នុងវីដេអូ។

### ជ្រើសរើសភាសា

### ជ្រើសរើសកម្រិត

កម្រិតត្រូវបានបែងចែកដើម្បីឲ្យអ្នកអាចរៀននៅតាមកម្រិតដែលស័ក្តិសមនឹងខ្លួនឯង។

### ប្រធានបទ និង គោលដៅ

បង្ហាញពីប្រធានបទនិងគោលដៅសម្រាប់ឈុតឆាកនីមួយៗ។

### ពាក្យគន្លឹះ

បង្ហាញពីពាក្យគន្លឹះដែលអាចរៀនបាននៅក្នុងគេហទំព័រនេះ។

### វីដេអូ

មានបង្ហាញវីដេអូយោងទៅតាមប្រធានបទ។

### ចំណងជើងរង

ការសន្ទនានឹងត្រូវបានបង្ហាញយោងទៅតាមវីដេអូ។ អ្នកអាចជ្រើសរើសចំណងជើងរងពីភាសាជប៉ុន រ៉ូម៉ាជិ និងភាសាបរទេស។

### ពាក្យដែលមានប្រយោជន៍

អាចមើលបញ្ជីពាក្យមានប្រយោជន៍ដែលទាក់ទងនឹងពាក្យលើកឡើងនៅក្នុងឈុតឆាកនីមួយៗ។



### ព័ត៌មានដែលមានប្រយោជន៍ (គូឡោន)

យើងតាំងផ្សាយនូវបទសម្ភាសន៍ដែលយើងបានសាកសួរជនបរទេសដែលរស់នៅក្នុងប្រទេសជប៉ុនអំពីបទពិសោធន៍របស់ពួកគេទាក់ទងនឹងប្រធានបទ។

### ព័ត៌មានដែលមានប្រយោជន៍ (វីដេអូ)

អ្នកអាចស្តាប់និងមើលវីដេអូនៃព័ត៌មាន ដែលដឹងហើយនឹងមានប្រយោជន៍ទាក់ទងទៅនឹងប្រធានបទសិក្សា។

## ចំណុច ៤ បង្ហាញពីចំណេះដឹងគ្រឹះរបស់ភាសាជប៉ុន

មានបង្ហាញព័ត៌មានល្អៗជាច្រើនដែលគួរដឹងទុកជាមុន មុននឹងចាប់ផ្តើមរៀនភាសាជប៉ុន ដូចជាលក្ខណៈពិសេសរបស់ភាសាជប៉ុន និងការបំបែកកិរិយាសព្ទជាដើម។




## ចំណុច ៥ គាំទ្រដល់ការរៀនអាននិងសរសេរផងដែរ

នៅក្នុងភាសាជប៉ុន មានអក្សរជាច្រើនប្រភេទ ហើយប្រហែលជាមានមនុស្សជាច្រើនដែលមានអារម្មណ៍ថាវាពិបាក។ នៅទីនេះ យើងនឹងធ្វើការណែនាំអំពីគន្លឹះសម្រាប់ការអាននិងការសរសេរ ព្រមទាំងរបៀបដែលអាចធ្វើឲ្យអ្នកមានអារម្មណ៍ស៊ាំនឹងការអាននិងការសរសេរ នៅក្នុងជីវភាពរស់នៅ។



## ចំណុច ៦ អ្នកអាចបញ្ជាក់មើលកម្រិតរបស់ខ្លួនឯងបាន

មុនពេលសិក្សាភាសាជប៉ុន អ្នកអាចបញ្ជាក់មើលថាតើកម្រិតជំនាញភាសាជប៉ុនរបស់ខ្លួនឯងត្រូវនឹងកម្រិតមួយណា។





# អាចរៀនតាមរយៈឈុតឆាកបែបនេះ

**ជាដំបូងសូមចងចាំ! ឃ្លាដែលមានប្រយោជន៍ជាភាសាជប៉ុន**

▼នៅខាងក្នុងហាងដែលច្រកផ្លូវតូចចង្អៀត



តើមិនអីទេឬ?
Daijoobu desu ka.

សូមអរគុណ។
Arigatoogozaimasu.

**កម្រិត១**

▼តើអ្នកសម្រេចចិត្តក្នុងការធ្វើការកុម្ម៉ង់រួចហើយឬនៅ?



តើអ្នកសម្រេចចិត្តក្នុងការធ្វើការកុម្ម៉ង់រួចហើយឬនៅ?
Gochuumon wa okimari desu ka.

ចាស ខ្ញុំចង់កុម្ម៉ង់មួយនេះ។
Hai, kore, onegaishimasu.

**កម្រិត២**

▼សូមអ្នកធ្វើបែបបទក្នុងការចុះឈ្មោះស្នាក់នៅ។



អញ្ចឹង សូមអ្នកធ្វើបែបបទក្នុងការចុះឈ្មោះស្នាក់នៅ។
Dewa, juumin-tooroku no tetsuzuki o onegaishimasu.

អ្វីទៅជា Juumin...tooroku...?
“Juumin…tooroku”…tte, nan desu ka.

**កម្រិត៣**

▼ថ្នាំនេះគឺសម្រាប់…។



សុំទោស ខ្ញុំភាគច្រើនក្លាយទៅជាងងុយគេង ក្រោយញុំាថ្នាំហើយ។ ចុះថ្នាំនេះយ៉ាងម៉េចដែរ?
Anoo, watashi, kusuri o nomu to, nemuku naru koto ga ooin desu kedo, kono kusuri wa doo desu ka.

បាទ ដូចមានសរសេរនៅទីនេះអញ្ចឹង រាងឆាប់ងងុយគេងបន្តិច។
Soo desu ne. Koko ni mo kaite arimasu kedo, chotto nemuku nari yasui desu yo.

## ឧបករណ៍ដែលមើលហើយយល់បាន




### វីដេអូផ្សព្វផ្សាយ

ទិដ្ឋភាពទូទៅនៃគេហទំព័រត្រូវបានពន្យល់ជាវីដេអូ។ (ដំណើរការជាមួយនឹងពហុភាសា)




### សៀវភៅណែនាំស្ដីពីការប្រើប្រាស់

យើងបានសង្ខេបយ៉ាងលម្អិតអំពីរបៀបដំណើរការការសិក្សានិងខ្លឹមសារបោះពុម្ពផ្សាយរបស់គេហទំព័រ។ (ភាសាជប៉ុនតែប៉ុណ្ណោះ)




### សៀវភៅណែនាំស្ដីពីការរៀន

របៀបរៀននៅ “Tsunahiro” តាមការមើលវីដេអូ

ជាវីដេអូដែលពន្យល់អំពីរបៀបរៀនដោយប្រើប្រាស់ Tsunahiro។ (ដំណើរការជាមួយនឹងពហុភាសា)

ទំនាក់ទំនង | ទីភ្នាក់ងារវប្បធម៌ ផ្នែកភាសាជាតិ

ទូរសព្ទ៖ ០៣ ៥២៥៣ ៤១១១ (តំណាង)
អ៊ីមែល៖ chiikinihongo@mext.go.jp

©Japanese Language Division, Agency for Cultural Affairs